# ការអនុវត្តអនុសាសន៍នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ ២ឆ្នាំក្រោយមក

ដំណើរការនៃការពិនិត្យជាសកលតាមកាលកំណត់("យូភីអ") លើកទី ៣ របស់ប្រទេសកម្ពុជាបានប្រព្រឹត្តទៅនៅក្នុងខែមករាឆ្នាំ២០១៩ ដែលនាពេលនោះរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិបានពិនិត្យកំណត់ត្រាសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជាទទួលបានអនុសាសន៍ចំនួន ១៩៨ ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សជាច្រើន។របាយការណ៍លទ្ធផលនៃការពិនិត្យត្រូវបានអនុម័តនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ ដោយរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ទទួលយកអនុសាសន៍ចំនួន ១៧៣ (ប្ដេជ្ញាក្នុងការអនុវត្ត និងកត់សម្គាល់ចំនួន ២៥ អនុសាសន៍)។ ពីរឆ្នាំកន្លងមក ចាប់តាំងពីការអនុម័តរបាយការណ៍លទ្ធផលនោះមានការវិវឌ្ឍមួយចំនួនក្នុងការអនុវត្តអនុសាសន៍ទាំងនេះ ហើយសម្រាប់អនុសាសន៍មួយចំនួនដែលស្នើឱ្យធ្វើកំណែទម្រង់ទៀតសោតនោះរឹតតែមានការប្រឈមកាន់តែខ្លាំងបើធៀបនឹងស្ថានភាពសិទ្ធិមនុស្សបច្ចុប្បន្ន។

## តើដំណើរការនៃការពិនិត្យជាសកលតាមកាលកំណត់ជាអ្វី?

ដំណើរការពិនិត្យជាសកលតាមកាលកំណត់ គឺជាយន្តការមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិដែលធ្វើការពិនិត្យលើការប្រតិបត្តិតាមកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សនៃរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ។ដំណើរការនេះប្រព្រឹត្តជាប្រចាំតាមវដ្ត ហើយរដ្ឋនីមួយៗទទួលការពិនិត្យនៅរៀងរាល់៥ឆ្នាំម្តង។នៅពេលបញ្ចប់ដំណើរការពិនិត្យយូភីអ រដ្ឋដែលស្ថិតក្រោមការពិនិត្យទទួលយកអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍លទ្ធផលដើម្បីកែលម្អស្ថានភាពសិទ្ធិមនុស្ស។ រដ្ឋអាចទទួលយក ឬកត់សម្គាល់អនុសាសន៍នីមួយៗ ហើយការទទួលយកមានន័យថាជាការប្តេជ្ញាចិត្តរបស់រដ្ឋក្នុងការអនុវត្តអនុសាសន៍នៅមុនការពិនិត្យនៅជុំបន្ទាប់។

## ពីរឆ្នាំក្រោយមក




## វឌ្ឍនភាព

### សិទ្ធិទទួលបានយុត្តិធម៌ រដ្ឋាភិបាលបានទទួលអនុសាសន៍ចំនួន ២៥ទាក់ទងនឹងសិទ្ធិទទួលបានយុត្តិធម៌

- ការបង្កើតសាលាឧទ្ធរណ៍ប្រចាំតំបន់ចំនួន ៣ នៅខេត្តបាត់ដំបងខេត្តព្រះសីហនុ និងខេត្តត្បូងឃ្មុំ។
- គម្រោងបើកមជ្ឈមណ្ឌលស្តារនីតិសម្បទាអនីតិជនលើកដំបូងនៅដើមឆ្នាំ២០២១។
- ការបើកសវនាការបញ្ចប់សំណុំរឿងកកស្ទះជាង៣៥.១០០ករណី ស្មើ៨៩% ដែលជាផ្នែកមួយនៃយុទ្ធនាការរបស់រដ្ឋាភិបាលដើម្បីកាត់បន្ថយចំនួនអ្នកទោសលើសចំនួននៅក្នុងពន្ធនាគារ។
- ការបង្កើនការផ្តល់ជំនួយផ្នែកច្បាប់ និងសេវាកម្មច្បាប់ឥតគិតថ្លៃដល់ជនក្រីក្រដែលបានគ្របដណ្តប់ប្រមាណ ៥០០០ ករណី។
- ការបង្កើតបណ្តាញទូរស័ព្ទបន្ទាន់ដើម្បីពិគ្រោះយោបល់ផ្នែកច្បាប់ដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាក្នុងគោលបំណងជួយដល់ពលរដ្ឋងាយរងគ្រោះនិងក្រីក្រ។
- ការបង្កើតការិយាល័យមេធាវីនៅតាមពន្ធនាគារទាំង២៥ ខេត្ត ក្រុង ដែលបង្កលក្ខណៈងាយស្រួលដល់មេធាវីក្នុងការពិគ្រោះយោបល់ជាលក្ខណៈឯកជនជាមួយកូនក្តី។
- ក្រសួងយុត្តិធម៌ ផ្សព្វផ្សាយសាលក្រមចំនួន៤៤ ពីរឿងរដ្ឋប្បវេណី ដើម្បីប្រើជាគំរូ។
- ក្រសួងមហាផ្ទៃបានបង្ហាញផែនការដាក់ពង្រាយមេធាវីតាមរយៈគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅតាមប៉ុស្តិ៍នគរបាលដើម្បីជួយក្នុងការដោះស្រាយបញ្ហាមូលដ្ឋាន។

## ការជួញដូរមនុស្ស

**រដ្ឋាភិបាលបានទទួលអនុសាសន៍ចំនួន ១២ ទាក់ទងនឹងការជួញដូរមនុស្សនៅកម្ពុជា**

- រដ្ឋាភិបាលបានដាក់ចេញនូវផែនការសកម្មភាពជាតិដើម្បីលំបាត់ការជួញដូរមនុស្សផ្លូវភេទ និងសរីរាង្គ ព្រមទាំងការបង្កើត បច្ចេកវិទ្យាថ្មីៗ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះនិងប្រមូលទិន្នន័យបានកាន់តែប្រសើរ។

## សមភាព

**រដ្ឋាភិបាលបានទទួលអនុសាសន៍ជាច្រើនទាក់ទងនឹងការកែលម្អសមភាពនៃក្រុមងាយរងគ្រោះ**

- ក្រសួងកិច្ចការនារីបានចុះហត្ថលេខាលើផែនការយុទ្ធសាស្ត្រយេនឌ័រ ៥ឆ្នាំ ថ្មីគឺ នារីរតនៈ ហើយរាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីសម្រាប់ ឆ្នាំ២០១៩-២០២៣ នៅខែមករាឆ្នាំ ២០២១ ។
- ការបណ្តុះបណ្តាលដល់ភ្នាក់ងារនគរបាលយុត្តិធម៌និងមន្ត្រីចំនួន ២៥ នាក់ នៅក្នុងខេត្តចំនួន៨អំពីបទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាយោបល់មូលដ្ឋានដល់ស្ត្រីនិងកុមារដែលជាជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ។
- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មបានកំណត់គោលដៅក្នុងការដាក់បញ្ចូលស្ត្រីឱ្យបានចំនួន៥០% នៅក្នុងកម្លាំងការងាររបស់ខ្លួន ហើយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រកាសថាគួរតែចាត់វិធានការដាក់ស្តែងដើម្បីបង្កើនចំនួនសមាមាត្រនៃស្ត្រីនៅក្នុងមុខតំណែងនៃការធ្វើសេចក្តីសម្រេចចិត្ត។
- រដ្ឋាភិបាលបានប្រកាសថា នឹងមានការបញ្ចូលមេរៀនអំពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀនក្នុងឆ្នាំ២០២០ ដើម្បីជួយលុបបំបាត់ការមាក់ងាយនិងការរើសអើង ។
- សមភាពនិងកិច្ចការពារជនមានពិការភាពការរីកចម្រើនតាមការអនុវត្តអនុសាសន៍ទាំងនេះគឺតាមរយៈផែនការវិភាជអត្ថប្រយោជន៍សម្រាប់ជនមានពិការភាព អនុញ្ញាតឱ្យជនមានពិការភាពមានសិទ្ធិទទួលបានប័ណ្ណបើកបរដោយស្របច្បាប់។
- ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់គ្រោងនឹងពន្លឿនការចុះបញ្ជីដីធ្លីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចដោយមានគោលបំណងចុះបញ្ជីដីធ្លីសហគមន៍យ៉ាងតិច១០ នៅឆ្នាំនេះ។





## ផ្នែកផ្សេង



- ការធ្វើសេចក្តីព្រាងច្បាប់សម្រាប់ការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ។ទោះជាយ៉ាងណាក្តីនៅក្នុងបរិយាកាសបច្ចុប្បន្នដែលការគោរពសិទ្ធិមនុស្សមានការប្រឈមនោះធ្វើឱ្យមានមន្ទិលថាតើស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនឹងមានប្រសិទ្ធភាពដែរឬទេហើយថាតើនឹងត្រូវបានបង្កើតឡើងស្របតាមគោលការណ៍ក្រុងប៉ារីសដែរឬទេ។
- កម្មវិធីឧបត្ថម្ភធនជាសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះនិងស្ត្រីដែលមានកូនតូចដែលមានអាយុតិចង២ ឆ្នាំ។



# ចំណុចពុំទាន់មានវឌ្ឍនភាព និងបញ្ហាប្រឈម

## សិទ្ធិដីធ្លី

**រដ្ឋាភិបាលបានទទួលយកអនុសាសន៍ចំនួន ៨ ទាក់ទងនឹងដីធ្លី និងបានកត់សម្គាល់ចំនួនពីរ**

- ករណីរំលោភសិទ្ធិដីធ្លី និងជម្លោះដីធ្លីនៅតែជាបញ្ហាកើតមានដ៏រាលដាលក្នុងប្រទេសកម្ពុជាដោយមានគ្រួសារជាច្រើនកំពុងត្រូវបានផ្លាស់ទីលំនៅដោយបង្ខំនៅ ឆ្នាំ២០២០ដើម្បីរៀបចំផ្លូវសម្រាប់គម្រោងអភិវឌ្ឍន៍ និងពុំមានការផ្តល់សំណង ត្រឹមត្រូវជូនពួកគាត់។



## លំហសេរីភាពពលរដ្ឋ

### អនុសាសន៍ចំនួនជាង២០ បានពិភាក្សាអំពីសារៈសំខាន់នៃការស្តារឡើងវិញនូវលំហសេរីភាពរបស់ពលរដ្ឋ



- រដ្ឋាភិបាលនៅតែបន្តកំណត់គោលដៅបង្ក្រាបទៅលើសង្គមស៊ីវិល គណបក្សជំទាស់ និងអ្នកការពារសិទ្ធិមនុស្ស បានកើនឡើង ដោយសកម្មជនជាច្រើន ត្រូវបានឃុំខ្លួននៅពាក់កណ្តាល ឆ្នាំ២០២០។
- តាមការសិក្សាដោយ ម.ស.ម.កបានរកឃើញថា៤០% នៃអង្គការសង្គមស៊ីវិល និងថ្នាក់ដឹកនាំសហជីពដែលត្រូវបានស្ទង់មតិសម្រាប់របាយការណ៍ឃ្លាំមើលសេរីភាពមូលដ្ឋានឆ្នាំ២០២០ បានលើកឡើងថាអាជ្ញាធរបានត្រួតពិនិត្យឬតាមដានសកម្មភាពរបស់ពួកគេ ។
- យ៉ាងហោចណាស់សមាជិក ឬ អ្នកគាំទ្រអតីតគណបក្សជំទាស់ចំនួន១៥១នាក់ ត្រូវបានចាប់ខ្លួននៅក្នុងអំឡុង ខែមេសា ឆ្នាំ២០១៩ ដល់ខែធ្នូ ឆ្នាំ២០២០ ដោយមួយចំនួនកំពុងស្ថិតក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន។
- នៅក្នុងខែវិច្ឆិកាឆ្នាំ ២០២០ រដ្ឋាភិបាលបានកោះហៅសកម្មជននិងអ្នកគាំទ្រអតីតគណបក្សសង្គ្រោះជាតិជាង ១៥០ នាក់ ឲ្យចូលរួមការជំនុំជម្រះចំពោះការចោទប្រកាន់ពីបទរៀបចំផែនការនិងញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋក្នុងគោលបំណងប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលបច្ចុប្បន្ន។
- នៅ ខែមករា ឆ្នាំ២០២០រដ្ឋាភិបាលបានអនុម័តវិសោធនកម្មច្បាប់ស្តីពីសហជីព តែច្បាប់នេះ មិនទាន់ស្របតាមបទដ្ឋានអន្តរជាតិដោយចំណុចសំខាន់ដែលស្នើឱ្យធ្វើការកែប្រែមិនត្រូវបានបញ្ចូលនោះទេ។
- ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ១៩ផ្តល់អំណាចដល់រដ្ឋាភិបាលយ៉ាងទូលំទូលាយ ដើម្បីអនុវត្តវិធានការណ៍ដែលរឹតត្បិតសិទ្ធិមនុស្សប្រសិនបើស្ថានភាពអាសន្នត្រូវបានប្រកាស។

## សេរីភាពនៃការប្រមូលផ្តុំ

### អនុសាសន៍ចំនួន ១៤ ត្រូវបានធ្វើឡើងដោយជំរុញឱ្យមានការការពារសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី

- ការប្រើប្រាស់កម្លាំងបង្ក្រាបការតវ៉ាក្នុងឆ្នាំ២០២០ មានការកើនឡើង ហើយ ម.ស.ម.កបានកត់ត្រា មានយ៉ាងតិច ៨ករណីនៃការប្រើប្រាស់កម្លាំងហួសប្រមាណ នៅចន្លោះខែកក្កដានិងកញ្ញា។
- គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រាការរឹតត្បិតចំនួន៧៦ លើសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធីរវាងខែមករា និងខែកញ្ញា ឆ្នាំ២០២០។
- នៅក្នុងខែសីហាឆ្នាំ២០២០ ក្រសួងយុត្តិធម៌បានហាមឃាត់ការតវ៉ាដែលអំពាវនាវឱ្យមានការដោះលែងលោក រ៉ុង ឈុន ដែលត្រូវបានឃុំខ្លួនហើយមនុស្សជាង១០នាក់ត្រូវបានចាប់ខ្លួនពីបទចូលរួមក្នុងការតវ៉ាបែបនេះ។
- នៅចុងឆ្នាំ ២០២០មានករណីជាច្រើននៃប្រព័ន្ធផ្សព្វផ្សាយនិងអ្នកសង្កេតការណ៍ការតវ៉ាត្រូវបានជ្រៀតជ្រែកក្នុងពេលព្យាយាមចងក្រងឯកសារការតវ៉ានានាដោយសន្តិវិធី។



## សេរីភាពបញ្ចេញមតិ

### មានការផ្តល់អនុសាសន៍ចំនួន ៣៣ ស្នើឱ្យមានការគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការការពារអ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ




- ការបង្ក្រាបលើអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយបានបន្តកាន់តែខ្លាំងឡើងៗ៖ អ្នកសារព័ត៌មានជាច្រើនត្រូវបានចាប់ខ្លួននិងផ្តន្ទាទោស ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនត្រូវបានដកហូតអាជ្ញាប័ណ្ណនិង អ្នកសារព័ត៌មានប្រឈមនិងការគំរាមកំហែងមិនឱ្យផ្សព្វផ្សាយ"ព័ត៌មានក្លែងក្លាយ" ហើយរដ្ឋាភិបាលបើកវគ្គបណ្តុះបណ្តាលដល់អ្នកសារព័ត៌មានដើម្បីចៀសវាងអនុវត្ត"ការងារខុសច្បាប់" ។
- នៅខែតុលា ឆ្នាំ២០២០ បន្ទាប់ពីការស៊ើបអង្កេតនិងការជំនុំជម្រះក្តីដែលកំពុងដំណើរការអស់រយៈពេល ៣ឆ្នាំ តុលាការជាន់ខ្ពស់ បានបញ្ជាក់ពីដីកាបង្គាប់ឱ្យធ្វើការស៊ើបអង្កេតឡើងវិញលើបទចោទប្រកាន់ចារកម្ម និងរូបអាសអាភាសលើអតីតអ្នកកាសែតវិទ្យុអាស៊ីសេរី គឺលោក អ៊ួន ឈិន និងលោក យិន សុជារិន ទោះបីមិនមានភ័ស្តុតាងដែលអាចជឿទុកចិត្តបានដែលភ្ជាប់ទំនាក់ទំនងរវាងអ្នកទាំងពីរទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក៏ដោយ។

## សេរីភាពបញ្ចេញមតិ (ត)



- អាជ្ញាធរបានដាក់ទណ្ឌកម្មលើទម្រង់នៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត ហើយបានផ្តន្ទាទោសស្ត្រីម្នាក់
- ឈ្មោះ ថៃ ស្រីនាង ដោយប្រើរូបអាសអាភាសពីបទបង្ហោះរូបភាពសិចស៊ីនៅលើហ្វេសប៊ុក។
- នៅខែសីហាឆ្នាំ២០២០រដ្ឋាភិបាលបានចេញសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈដែលដាក់កម្រិត លើសេរីភាពនៃការបញ្ចេញមតិរួមទាំងការដាក់បម្រាមគោចរ ការធ្វើនិយ័តកម្មលើការជ្រើសរើស សម្លៀកបំពាក់និងការរឹតត្បិតលើបញ្ហាមួយចំនួន។

## សេរីភាពនៅលើអ៊ីនធឺណិត



- ប្រជាពលរដ្ឋកំពុងត្រូវបានគម្រាមកំហែង យាយី និងរងការចោទប្រកាន់ពីបទផ្សព្វផ្សាយ "ដំណឹងក្លែងក្លាយ" ក្នុងការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនៅលើបណ្តាញអ៊ីនធឺណិត។ ពលរដ្ឋជាង ៤០ នាក់ត្រូវបានចាប់ខ្លួនពីបទ" ដំណឹងក្លែងក្លាយ"ក្នុងឆ្នាំ២០២០ ។
នៅខែកក្កដានិងសីហា ឆ្នាំ២០២០សេចក្តីព្រាងច្បាប់ចំនួនពីរត្រូវបានព្រាង គឺសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ិនធឺណេតជាតិនិងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតដែលត្រូវបានធ្វើបច្ចុប្បន្នភាព។ប្រសិនបើត្រូវបានអនុម័ត ច្បាប់ទាំងពីរនេះនឹងផ្តល់អំណាចដល់រដ្ឋាភិបាលដើម្បីធ្វើការឃ្លាំមើល និងត្រួតពិនិត្យលើការបញ្ចេញមតិតាមអ៊ិនធឺណេត។




## ផ្សេងៗ

- និទណ្ឌភាពនៅតែជាក្តីកង្វល់ខ្លាំងមួយសម្រាប់ប្រទេសកម្ពុជាករណីពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសលើអ្នកការពារសិទ្ធិមនុស្ស សមាជិកអតីតគណបក្សសង្គ្រោះជាតិ និងអ្នកសារព័ត៌មានកម្រយើញជនបង្ក ឬអ្នកពាក់ព័ន្ធទទួលខុសត្រូវណាស់។
- យុទ្ធនាការ "បង្ក្រាបគ្រឿងញៀន" ពុំបានទប់ស្កាត់អោយមានប្រសិទ្ធិភាពលើការប្រើប្រាស់គ្រឿងញៀនទេនិងមានការរំលោភបំពានសិទ្ធិមនុស្សដែលធ្វើឱ្យប៉ះពាល់ដល់ស្ត្រីដោយពុំសមាមាត្រ ជាពិសេសនៅពេលជាប់គុកជាមួយកូនៗ របស់ពួកគេ។
- ភាពចង្អៀតណែននៅក្នុងពន្ធនាគារនៅតែជាបញ្ហាដោយអត្រាកាន់កាប់ជាមធ្យមនៃពន្ធនាគារក្នុងប្រទេសមានច្រើនជាង ៣០០%ចាប់ពីចន្លោះខែមិថុនាឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២០ ។
- ហេដ្ឋារចនាសម្ព័ន្ធដែលឆ្លើយតបទៅនឹងតម្រូវការរបស់ជនមានពិការភាពនៅពុំទាន់គ្រប់គ្រាន់ឬស្របទៅតាមស្តង់ដារនៅឡើយ។



## សេចក្តីសន្និដ្ឋាន

តាមរយៈដំណើរការពិនិត្យជាសកលតាមកាលកំណត់ទាំង៣ ជុំកន្លងមកប្រទេសកម្ពុជាបានបង្ហាញឆន្ទៈក្នុងការទទួលយកអនុសាសន៍ជាបន្តបន្ទាប់ដោយទទួលយកអនុសាសន៍ជាង៨៨%។តែយ៉ាងណាក្តីអនុសន៍ភាគច្រើនដែលរដ្ឋាភិបាលបានទទួលយកនៅយូភីអ ជុំទីមួយ និងជុំទីពីរ នៅមិនទាន់បានអនុវត្តនៅឡើយ។ ថ្វីបើមានការវិវត្តវិជ្ជមានមួយចំនួនក្នុងការអនុវត្តអនុសាសន៍នៅជុំទី៣ នេះមានកិច្ចការជាច្រើនទៀតដែលរដ្ឋាភិបាលត្រូវបំពេញតាមការប្តេជ្ញារបស់ខ្លួន។

សូមអានបន្ថែមតាមរយៈ: sithi.org/upr

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
cchrcambodia.org
@CCHRCambodia
sithi.org

CC BY NC SA

ខែ មករា ឆ្នាំ២០២១